មាត្រា៣: អនុគណៈកម្មាធិការវិនិយោគខេត្តកំពង់ធំ ត្រូវដំណើរការការងារទៅតាមនីតិវិធីនៃច្បាប់ និងបទប្បញ្ញត្តិស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការចុះបញ្ជីសំណើវិនិយោគរបស់ក្រុមហ៊ុនថ្មី ជាគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ចំពោះគំរោងដែលមានទុនវិនិយោគទាបជាង០២(ពីរ)លានដុល្លារអាមេរិក ។

មាត្រា៤: អនុគណៈកម្មាធិការវិនិយោគខេត្តកំពង់ធំ ត្រូវផ្តល់ឯកសារពាក់ព័ន្ធនឹងគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា បន្ទាប់ពីបានចុះបញ្ជីវិនិយោគរួចហើយ ដើម្បីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា មានមូលដ្ឋានក្នុងការពិនិត្យ និងផ្តល់ការលើកទឹកចិត្តលើសំណើនាំចូលរបស់អ្នកវិនិយោគ ។

មាត្រា៥: គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវធ្វើប្រតិភូកម្មអំណាចជូនគ្រប់មន្ទីរ-អង្គភាពក្នុងខេត្តកំពង់ធំ ជាខ្សែបណ្តោយរបស់ខ្លួន នូវសិទ្ធិសំរេចក្នុងនាមក្រសួង-ស្ថាប័ន ដោយត្រូវចេញបទប្បញ្ញត្តិណែនាំលំអិតដល់មន្ត្រីក្រោមឱវាទ ស្តីពីកិច្ចដំណើរការ និងនីតិវិធី ដែលត្រូវអនុវត្តចំពោះកិច្ចការពាក់ព័ន្ធដល់ការចេញលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ ការយល់ព្រមនានាក្នុងនាមក្រសួង-ស្ថាប័នរបស់ខ្លួន ។

មាត្រា៦: គំរោងវិនិយោគដូចខាងក្រោម មិនឆ្លងការពិនិត្យសំរេចក្នុងការចុះបញ្ជីសំណើវិនិយោគរបស់អនុគណៈកម្មាធិការវិនិយោគខេត្តកំពង់ធំទេ ដោយត្រូវឆ្លងការចុះបញ្ជីក្រោមយន្តការរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/ គណៈកម្មាធិការវិនិយោគកម្ពុជា :

១- គំរោងមានទំហំទុនវិនិយោគចាប់ពី ០២(ពីរ) លានដុល្លារអាមេរិកឡើងទៅ ។

២- គំរោងវិនិយោគដែលមានទីតាំងស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ខេត្ត-ក្រុង ចាប់ពីពីរឡើងទៅ ។

៣- គំរោងវិនិយោគដែលស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ។

មាត្រា៧: នីតិវិធីនៃការចុះបញ្ជីសំណើវិនិយោគ និងផ្តល់ការលើកទឹកចិត្តវិនិយោគរបស់អនុគណៈកម្មាធិការវិនិយោគខេត្តកំពង់ធំ គឺ :

- ដើរតួជាយន្តការច្រកចេញ-ចូលតែមួយលើការងារវិនិយោគនៅក្នុងខេត្ត
- ត្រូវអនុវត្តតាមនីតិវិធី ដោយផ្អែកលើច្បាប់-បទប្បញ្ញត្តិស្តីពីវិនិយោគជាធរមាន ដូចដែលអនុវត្តនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជាដែរ ។

មាត្រា៨: ការវិនិយោគទាំងឡាយណា ដែលបានទទួលការអនុញ្ញាតដោយច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ និងអនុក្រឹត្យពាក់ព័ន្ធនានា ត្រូវចាត់ទុកជាគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្រោយពេលអ្នកវិនិយោគបានបំពេញរាល់បែបបទតាមនីតិវិធីកំណត់ ដូចមានចែងក្នុងអនុក្រឹត្យ ស្តីពីការណែនាំអនុវត្តច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា៩: - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញបទប្បញ្ញត្តិ ស្តីពីការណែនាំអនុវត្តជាក់ស្តែង និងធ្វើការបណ្តុះបណ្តាលមុខជំនាញដល់អនុគណៈកម្មាធិការវិនិយោគខេត្តកំពង់ធំ ដើម្បីធានាអោយដំណើរការនៃយន្តការនេះប្រព្រឹត្តិទៅមានភាពរលូន និងមានប្រសិទ្ធភាពខ្ពស់ ។

- អនុគណៈកម្មាធិការវិនិយោគខេត្តកំពង់ធំ ត្រូវធ្វើរបាយការណ៍ប្រចាំខែមកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា ដើម្បីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា មានមូលដ្ឋានគ្រប់គ្រាន់សំរាប់ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល ។

មាត្រា១០: សហប្រធាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី-សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ-រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម-រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល-រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន-រដ្ឋមន្ត្រីក្រសួងបរិស្ថាន-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់-រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ-រដ្ឋមន្ត្រីក្រសួងផែនការ-រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម-រដ្ឋមន្ត្រីក្រសួងទេសចរណ៍-រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍-រដ្ឋមន្ត្រីគ្រប់ក្រសួង-អភិបាលខេត្តកំពង់ធំ-អភិបាលគ្រប់ខេត្ត/ក្រុង-គ្រប់ប្រធានស្ថាប័ន/អង្គភាពដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងមាត្រា១ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

គាត ឈន់

__កន្លែងទទួល__

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី សហប្រធាន"ក.អ.ក"
- ខុទ្ទកាល័យសម្តេចក្រុមព្រះ សហប្រធាន"ក.អ.ក"
- ដូចមាត្រា ១០ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតអនុគណៈកម្មាធិការវិនិយោគខេត្តស្វាយរៀង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃ ទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុក្រឹត្យស្តីពីការធ្វើវិសោធនកម្មជាបន្តបន្ទាប់លេខ១១២ អនក្រ.បក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០២ និងលេខ៣៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៤
- យោងអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យស្តីពីការធ្វើវិសោធនកម្មជាបន្តបន្ទាប់លេខ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ និងលេខ១៣០ អនក្រ.បក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០១
- យោងតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការជំរុញចលនាប្រលងប្រណាំងទាក់ទាញការវិនិយោគឯកជនតាមបណ្តាខេត្ត-ក្រុង
- យោងសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

សម្រេច

មាត្រា១: បង្កើតយន្តការចុះបញ្ជីសំណើវិនិយោគ ជាក់រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នៅខេត្តស្វាយរៀង ដែលមានឈ្មោះថា **អនុគណៈកម្មាធិការវិនិយោគខេត្តស្វាយរៀង** "អ.គ.វ.ខ.ស្វរ" និងដែលមានសមាសភាព ដូចខាងក្រោម :

១- អភិបាលខេត្ត	ប្រធាន
២- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា	អនុប្រធានអចិន្ត្រៃយ៍
៣- អភិបាលរងទី១ខេត្ត	អនុប្រធាន
៤- អភិបាលរងទី២ខេត្ត	អនុប្រធាន
៥- ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៦- ប្រធានមន្ទីរពាណិជ្ជកម្ម	សមាជិក
៧- ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល	សមាជិក
៨- ប្រធានមន្ទីរសាធារណការ និង ដឹកជញ្ជូន	សមាជិក
៩- ប្រធានមន្ទីរបរិស្ថាន	សមាជិក
១០- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី	សមាជិក
១១- ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
១២- ប្រធានមន្ទីរផែនការ	សមាជិក
១៣- ប្រធានមន្ទីរធនធានទឹក និងឧតុនិយម	សមាជិក
១៤- ប្រធានមន្ទីរទេសចរណ៍	សមាជិក
១៥- ប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍	សមាជិក
១៦- តំណាងសភាពាណិជ្ជកម្មខេត្ត	សមាជិកសង្កេតការណ៍
១៧- តំណាងលេខាធិការដ្ឋាន	លេខាធិការ

សមាសភាពដែលមានចែងខាងលើ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធានក្នុងករណីប្រធានអវត្តមាន ។

គ្រប់មន្ទីរ-អង្គភាពពាក់ព័ន្ធ-អភិបាលស្រុកក្នុងខេត្តស្វាយរៀង ដែលមិនមែនជាសមាជិករបស់អនុគណៈកម្មាធិការវិនិយោគខេត្តស្វាយរៀងនោះ នឹងត្រូវអញ្ជើញចូលរួមប្រជុំតាមករណីពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួន ។

មាត្រា២: - អនុគណៈកម្មាធិការវិនិយោគខេត្តស្វាយរៀង ត្រូវមានលេខាធិការដ្ឋានមួយ សំរាប់ដោះស្រាយការងារប្រចាំថ្ងៃរបស់ខ្លួន ដឹកនាំដោយអនុប្រធានអចិន្ត្រៃយ៍ នៃអនុគណៈកម្មាធិការវិនិយោគខេត្ត ។

- អនុគណៈកម្មាធិការវិនិយោគខេត្តស្វាយរៀង មានសិទ្ធិប្រើប្រាស់ជាផ្លូវការនូវត្រាដោយឡែក សំរាប់កិច្ចដំណើរការការងាររបស់ខ្លួន ។

មាត្រា៣: អនុគណៈកម្មាធិការវិនិយោគខេត្តស្វាយរៀង ត្រូវដំណើរការការងារទៅតាមនីតិវិធីនៃច្បាប់ និងបទបញ្ញត្តិស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការចុះបញ្ជីសំណើវិនិយោគរបស់ក្រុមហ៊ុនថ្មី ជាគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ចំពោះគំរោងដែលមានទុនវិនិយោគទាបជាង០២(ពីរ) លានដុល្លារអាមេរិក ។

មាត្រា៤: អនុគណៈកម្មាធិការវិនិយោគខេត្តស្វាយរៀង ត្រូវផ្តល់ឯកសារពាក់ព័ន្ធនឹងគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា បន្ទាប់ពីបានចុះបញ្ជីវិនិយោគរួចហើយ ដើម្បីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា មានមូលដ្ឋានក្នុងការពិនិត្យ និងផ្តល់ការលើកទឹកចិត្តលើសំណើនាំចូលរបស់អ្នកវិនិយោគ ។

មាត្រា៥: គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវធ្វើប្រតិភូកម្មអំណាចជូនគ្រប់មន្ទីរ-អង្គភាពក្នុងខេត្តស្វាយរៀង ជាខ្សែបណ្តោយរបស់ខ្លួន នូវសិទ្ធិសំរេចក្នុងនាមក្រសួង-ស្ថាប័ន ដោយត្រូវចេញបទបញ្ញត្តិណែនាំលំអិតដល់មន្ត្រីក្រោមឱវាទ ស្តីពីកិច្ចដំណើរការ និងនីតិវិធី ដែលត្រូវអនុវត្តចំពោះកិច្ចការពាក់ព័ន្ធដល់ការចេញលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ ការយល់ព្រមនានាក្នុងនាមក្រសួង-ស្ថាប័នរបស់ខ្លួន ។

មាត្រា៦: គំរោងវិនិយោគដូចខាងក្រោម មិនឆ្លងការពិនិត្យសំរេចក្នុងការចុះបញ្ជីសំណើវិនិយោគរបស់អនុគណៈកម្មាធិការវិនិយោគខេត្តស្វាយរៀងទេ ដោយត្រូវឆ្លងការចុះបញ្ជីក្រោមយន្តការរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/ គណៈកម្មាធិការវិនិយោគកម្ពុជា :

១- គំរោងមានទំហំទុនវិនិយោគចាប់ពី ០២(ពីរ) លានដុល្លារអាមេរិកឡើងទៅ ។

២- គំរោងវិនិយោគដែលមានទីតាំងស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ខេត្ត-ក្រុង ចាប់ពីពីរឡើងទៅ ។

៣- គំរោងវិនិយោគដែលស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ។

មាត្រា៧: នីតិវិធីនៃការចុះបញ្ជីសំណើវិនិយោគ និងផ្តល់ការលើកទឹកចិត្តវិនិយោគរបស់អនុគណៈកម្មាធិការវិនិយោគខេត្តស្វាយរៀង គឺ :

- ដើរតួជាយន្តការច្រកចេញ-ចូលតែមួយលើការងារវិនិយោគនៅក្នុងខេត្ត
- ត្រូវអនុវត្តតាមនីតិវិធី ដោយផ្អែកលើច្បាប់-បទបញ្ញត្តិស្តីពីវិនិយោគជាធរមាន ដូចដែលអនុវត្តនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជាដែរ ។

មាត្រា៨: ការវិនិយោគទាំងឡាយណា ដែលបានទទួលការអនុញ្ញាតដោយច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ និងអនុក្រឹត្យពាក់ព័ន្ធនានា ត្រូវចាត់ទុកជាគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្រោយពេលអ្នកវិនិយោគបានបំពេញរាល់បែបបទតាមនីតិវិធីកំណត់ ដូចមានចែងក្នុងអនុក្រឹត្យ ស្តីពីការណែនាំអនុវត្តច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា៩:
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញបទប្បញ្ញត្តិ ស្តីពីការណែនាំអនុវត្តជាក់ស្តែង និងធ្វើការបណ្តុះបណ្តាលមុខជំនាញដល់អនុគណៈកម្មាធិការវិនិយោគខេត្តស្វាយរៀង ដើម្បីធានាអោយដំណើរការនៃយន្តការនេះប្រព្រឹត្តិទៅមានភាពរលូន និងមានប្រសិទ្ធភាពខ្ពស់ ។
- អនុគណៈកម្មាធិការវិនិយោគខេត្តស្វាយរៀង ត្រូវធ្វើរបាយការណ៍ប្រចាំខែមកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា ដើម្បីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា មានមូលដ្ឋានគ្រប់គ្រាន់សំរាប់ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល ។

មាត្រា១០: សហប្រធាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី-សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ-រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម-រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល-រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន-រដ្ឋមន្ត្រីក្រសួងបរិស្ថាន-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់-រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ-រដ្ឋមន្ត្រីក្រសួងផែនការ-រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម-រដ្ឋមន្ត្រីក្រសួងទេសចរណ៍-រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍-រដ្ឋមន្ត្រីគ្រប់ក្រសួង-អភិបាលខេត្តស្វាយរៀង-អភិបាលគ្រប់ខេត្ត/ក្រុង-គ្រប់ប្រធានស្ថាប័ន/អង្គភាពដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងមាត្រា១ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

គាត ឈន់

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី សហប្រធាន "ក.អ.ក"
- ខុទ្ទកាល័យសម្តេចក្រុមព្រះ សហប្រធាន "ក.អ.ក"
- ដូចមាត្រា ១០ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧២ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតអនុគណៈកម្មាធិការវិនិយោគខេត្តពោធិ៍សាត់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃ ទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុក្រឹត្យស្តីពីការធ្វើវិសោធនកម្មជាបន្តបន្ទាប់លេខ១១២ អនក្រ.បក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០២ និងលេខ៣៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៤
- យោងអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យស្តីពីការធ្វើវិសោធនកម្មជាបន្តបន្ទាប់លេខ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ និងលេខ១៣០ អនក្រ.បក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០១
- យោងតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការជំរុញចលនាប្រលងប្រណាំងទាក់ទាញការវិនិយោគឯកជនតាមបណ្តាខេត្ត-ក្រុង
- យោងសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

សម្រេច

មាត្រា១: បង្កើតយន្តការចុះបញ្ជីសំណើវិនិយោគ ជាគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នៅខេត្តពោធិ៍សាត់ ដែលមានឈ្មោះថា **អនុគណៈកម្មាធិការវិនិយោគខេត្តពោធិ៍សាត់** "អ.គ.វ.ខ.ពស" និងដែលមានសមាសភាព ដូចខាងក្រោម :

១- អភិបាលខេត្ត	ប្រធាន
២- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា	អនុប្រធានអចិន្ត្រៃយ៍
៣- អភិបាលរងទី១ខេត្ត	អនុប្រធាន
៤- អភិបាលរងទី២ខេត្ត	អនុប្រធាន
៥- ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៦- ប្រធានមន្ទីរពាណិជ្ជកម្ម	សមាជិក
៧- ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល	សមាជិក
៨- ប្រធានមន្ទីរសាធារណការ និង ដឹកជញ្ជូន	សមាជិក
៩- ប្រធានមន្ទីរបរិស្ថាន	សមាជិក
១០- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី	សមាជិក
១១- ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
១២- ប្រធានមន្ទីរផែនការ	សមាជិក
១៣- ប្រធានមន្ទីរធនធានទឹក និងឧតុនិយម	សមាជិក
១៤- ប្រធានមន្ទីរទេសចរណ៍	សមាជិក
១៥- ប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍	សមាជិក
១៦- តំណាងសភាពាណិជ្ជកម្មខេត្ត	សមាជិកសង្កេតការណ៍
១៧- តំណាងលេខាធិការដ្ឋាន	លេខាធិការ

សមាសភាពដែលមានចែងខាងលើ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធានក្នុងករណីប្រធានអវត្តមាន ។

គ្រប់មន្ទីរ-អង្គភាពពាក់ព័ន្ធ-អភិបាលស្រុកក្នុងខេត្តពោធិ៍សាត់ ដែលមិនមែនជាសមាជិករបស់អនុគណៈកម្មាធិការវិនិយោគខេត្តពោធិ៍សាត់នោះ នឹងត្រូវអញ្ជើញចូលរួមប្រជុំតាមករណីពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួន។

មាត្រា២: - អនុគណៈកម្មាធិការវិនិយោគខេត្តពោធិ៍សាត់ ត្រូវមានលេខាធិការដ្ឋានមួយ សំរាប់ដោះស្រាយការងារប្រចាំថ្ងៃរបស់ខ្លួន ដឹកនាំដោយអនុប្រធានអចិន្ត្រៃយ៍ នៃអនុគណៈកម្មាធិការវិនិយោគខេត្ត។

- អនុគណៈកម្មាធិការវិនិយោគខេត្តពោធិ៍សាត់ មានសិទ្ធិប្រើប្រាស់ជាផ្លូវការនូវត្រាដោយឡែក សំរាប់កិច្ចដំណើរការការងាររបស់ខ្លួន ។

មាត្រា៣: អនុគណៈកម្មាធិការវិនិយោគខេត្តពោធិ៍សាត់ ត្រូវដំណើរការការងារទៅតាមនីតិវិធីនៃច្បាប់ និងបទប្បញ្ញត្តិស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការចុះបញ្ជីសំណើវិនិយោគរបស់ក្រុមហ៊ុនថ្មី ជាគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ចំពោះគំរោងដែលមានទុនវិនិយោគទាបជាង០២(ពីរ) លានដុល្លារអាមេរិក ។

មាត្រា៤: អនុគណៈកម្មាធិការវិនិយោគខេត្តពោធិ៍សាត់ ត្រូវផ្តល់ឯកសារពាក់ព័ន្ធនឹងគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា បន្ទាប់ពីបានចុះបញ្ជីវិនិយោគរួចហើយ ដើម្បីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា មានមូលដ្ឋានក្នុងការពិនិត្យ និងផ្តល់ការលើកទឹកចិត្តលើសំណើនាំចូលរបស់អ្នកវិនិយោគ ។

មាត្រា៥: គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវធ្វើប្រតិភូកម្មអំណាចជូនគ្រប់មន្ទីរ-អង្គភាពក្នុងខេត្តពោធិ៍សាត់ ជាខ្សែបណ្តោយរបស់ខ្លួន នូវសិទ្ធិសំរេចក្នុងនាមក្រសួង-ស្ថាប័ន ដោយត្រូវចេញបទប្បញ្ញត្តិណែនាំលំអិតដល់មន្ត្រីក្រោមឱវាទ ស្តីពីកិច្ចដំណើរការ និងនីតិវិធី ដែលត្រូវអនុវត្តចំពោះកិច្ចការពាក់ព័ន្ធដល់ការចេញលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ ការយល់ព្រមនានាក្នុងនាមក្រសួង-ស្ថាប័នរបស់ខ្លួន ។

មាត្រា៦: គំរោងវិនិយោគដូចខាងក្រោម មិនឆ្លងការពិនិត្យសំរេចក្នុងការចុះបញ្ជីសំណើវិនិយោគរបស់អនុគណៈកម្មាធិការវិនិយោគខេត្តពោធិ៍សាត់ទេ ដោយត្រូវឆ្លងការចុះបញ្ជីក្រោមយន្តការរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/ គណៈកម្មាធិការវិនិយោគកម្ពុជា :

១- គំរោងមានទំហំទុនវិនិយោគចាប់ពី ០២(ពីរ) លានដុល្លារអាមេរិកឡើងទៅ ។

២- គំរោងវិនិយោគដែលមានទីតាំងស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ខេត្ត-ក្រុង ចាប់ពីពីរឡើងទៅ ។

៣- គំរោងវិនិយោគដែលស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ។

មាត្រា៧: នីតិវិធីនៃការចុះបញ្ជីសំណើវិនិយោគ និងផ្តល់ការលើកទឹកចិត្តវិនិយោគរបស់អនុគណៈកម្មាធិការវិនិយោគខេត្តពោធិ៍សាត់ គឺ :

- ដើរតួជាយន្តការច្រកចេញ-ចូលតែមួយលើការងារវិនិយោគនៅក្នុងខេត្ត
- ត្រូវអនុវត្តតាមនីតិវិធី ដោយផ្អែកលើច្បាប់-បទប្បញ្ញត្តិស្តីពីវិនិយោគជាធរមាន ដូចដែលអនុវត្តនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជាដែរ ។

មាត្រា៨: ការវិនិយោគទាំងឡាយណា ដែលបានទទួលការអនុញ្ញាតដោយច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ និងអនុក្រឹត្យពាក់ព័ន្ធនានា ត្រូវចាត់ទុកជាគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្រោយពេលអ្នកវិនិយោគបានបំពេញរាល់បែបបទតាមនីតិវិធីកំណត់ ដូចមានចែងក្នុងអនុក្រឹត្យ ស្តីពីការណែនាំអនុវត្តច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា៩: - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញបទប្បញ្ញត្តិ ស្ដីពីការណែនាំអនុវត្តជាក់ស្ដែង និងធ្វើការបណ្ដុះបណ្ដាលមុខជំនាញដល់អនុគណៈកម្មាធិការវិនិយោគខេត្តពោធិ៍សាត់ ដើម្បីធានាអោយដំណើរការនៃយន្តការនេះប្រព្រឹត្តិទៅមានភាពរលូន និងមានប្រសិទ្ធភាពខ្ពស់ ។

- អនុគណៈកម្មាធិការវិនិយោគខេត្តពោធិ៍សាត់ ត្រូវធ្វើរបាយការណ៍ប្រចាំខែមកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា ដើម្បីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា មានមូលដ្ឋានគ្រប់គ្រាន់សំរាប់ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល ។

មាត្រា១០: សហប្រធាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា-រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី-សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ-រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម-រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល-រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន-រដ្ឋមន្ត្រីក្រសួងបរិស្ថាន-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់-រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ-រដ្ឋមន្ត្រីក្រសួងផែនការ-រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម-រដ្ឋមន្ត្រីក្រសួងទេសចរណ៍-រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍-រដ្ឋមន្ត្រីគ្រប់ក្រសួង-អភិបាលខេត្តពោធិ៍សាត់-អភិបាលគ្រប់ខេត្ត/ក្រុង-គ្រប់ប្រធានស្ថាប័ន/អង្គភាពដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងមាត្រា១ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានជំរាបជូន

សម្ដេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

គាត ឈន់

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី សហប្រធាន "ក.អ.ក"
- ខុទ្ទកាល័យសម្ដេចក្រុមព្រះ សហប្រធាន "ក.អ.ក"
- ដូចមាត្រា ១០ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតអនុគណៈកម្មាធិការវិនិយោគខេត្តព្រៃវែង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃ ទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុក្រឹត្យស្តីពីការធ្វើវិសោធនកម្មជាបន្តបន្ទាប់លេខ១១២ អនក្រ.បក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០២ និងលេខ៣៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៤
- យោងអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យស្តីពីការធ្វើវិសោធនកម្មជាបន្តបន្ទាប់លេខ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ និងលេខ១៣០ អនក្រ.បក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០១
- យោងតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការជំរុញចលនាប្រលងប្រណាំងទាក់ទាញការវិនិយោគឯកជនតាមបណ្តាខេត្ត-ក្រុង
- យោងសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

សម្រេច

មាត្រា១: បង្កើតយន្តការចុះបញ្ជីសំណើវិនិយោគ ជាតំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នៅខេត្តព្រៃវែង ដែលមានឈ្មោះថា **អនុគណៈកម្មាធិការវិនិយោគខេត្តព្រៃវែង** "អ.គ.វ.ខ.ពវ" និងដែលមានសមាសភាព ដូចខាងក្រោម :

១- អភិបាលខេត្ត	ប្រធាន
២- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា	អនុប្រធានអចិន្ត្រៃយ៍
៣- អភិបាលរងទី១ខេត្ត	អនុប្រធាន
៤- អភិបាលរងទី២ខេត្ត	អនុប្រធាន
៥- ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៦- ប្រធានមន្ទីរពាណិជ្ជកម្ម	សមាជិក
៧- ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល	សមាជិក
៨- ប្រធានមន្ទីរសាធារណការ និង ដឹកជញ្ជូន	សមាជិក
៩- ប្រធានមន្ទីរបរិស្ថាន	សមាជិក
១០- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី	សមាជិក
១១- ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
១២- ប្រធានមន្ទីរផែនការ	សមាជិក
១៣- ប្រធានមន្ទីរធនធានទឹក និងឧតុនិយម	សមាជិក
១៤- ប្រធានមន្ទីរទេសចរណ៍	សមាជិក
១៥- ប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍	សមាជិក
១៦- តំណាងសភាពាណិជ្ជកម្មខេត្ត	សមាជិកសង្កេតការណ៍
១៧- តំណាងលេខាធិការដ្ឋាន	លេខាធិការ

សមាសភាពដែលមានចែងខាងលើ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន ក្នុងករណីប្រធានអវត្តមាន ។

គ្រប់មន្ទីរ-អង្គភាពពាក់ព័ន្ធ-អភិបាលស្រុកក្នុងខេត្តព្រៃវែង ដែលមិនមែនជាសមាជិករបស់អនុគណៈកម្មាធិការវិនិយោគខេត្តព្រៃវែងនោះ នឹងត្រូវអញ្ជើញចូលរួមប្រជុំតាមករណីពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួន ។

មាត្រា២: - អនុគណៈកម្មាធិការវិនិយោគខេត្តព្រៃវែង ត្រូវមានលេខាធិការដ្ឋានមួយ សំរាប់ដោះស្រាយការងារប្រចាំថ្ងៃរបស់ខ្លួន ដឹកនាំដោយអនុប្រធានអចិន្ត្រៃយ៍ នៃអនុគណៈកម្មាធិការវិនិយោគខេត្ត ។

- អនុគណៈកម្មាធិការវិនិយោគខេត្តព្រៃវែង មានសិទ្ធិប្រើប្រាស់ជាផ្លូវការនូវត្រាដោយឡែក សំរាប់កិច្ចដំណើរការការងាររបស់ខ្លួន ។

មាត្រា៣: អនុគណៈកម្មាធិការវិនិយោគខេត្តព្រៃវែង ត្រូវដំណើរការការងារទៅតាមនីតិវិធីនៃច្បាប់ និងបទប្បញ្ញត្តិស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការចុះបញ្ជីសំណើវិនិយោគរបស់ក្រុមហ៊ុនថ្មី ជាគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ចំពោះគំរោងដែលមានទុនវិនិយោគទាបជាង០២(ពីរ) លានដុល្លារអាមេរិក ។

មាត្រា៤: អនុគណៈកម្មាធិការវិនិយោគខេត្តព្រៃវែង ត្រូវផ្តល់ឯកសារពាក់ព័ន្ធនឹងគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា បន្ទាប់ពីបានចុះបញ្ជីវិនិយោគរួចហើយ ដើម្បីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា មានមូលដ្ឋានក្នុងការពិនិត្យ និងផ្តល់ការលើកទឹកចិត្តលើសំណើនាំចូលរបស់អ្នកវិនិយោគ ។

មាត្រា៥: គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវធ្វើប្រតិភូកម្មអំណាចជូនគ្រប់មន្ទីរ-អង្គភាពក្នុងខេត្តព្រៃវែង ជាខ្សែបណ្តោយរបស់ខ្លួន នូវសិទ្ធិសំរេចក្នុងនាមក្រសួង-ស្ថាប័ន ដោយត្រូវចេញបទប្បញ្ញត្តិណែនាំលំអិតដល់មន្ត្រីក្រោមឱវាទ ស្តីពីកិច្ចដំណើរការ និងនីតិវិធី ដែលត្រូវអនុវត្តចំពោះកិច្ចការពាក់ព័ន្ធដល់ការចេញលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ ការយល់ព្រមនានាក្នុងនាមក្រសួង-ស្ថាប័នរបស់ខ្លួន ។

មាត្រា៦: គំរោងវិនិយោគដូចខាងក្រោម មិនឆ្លងការពិនិត្យសំរេចក្នុងការចុះបញ្ជីសំណើវិនិយោគរបស់អនុគណៈកម្មាធិការវិនិយោគខេត្តព្រៃវែងទេ ដោយត្រូវឆ្លងការចុះបញ្ជីក្រោមយន្តការរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/ គណៈកម្មាធិការវិនិយោគកម្ពុជា :

១- គំរោងមានទំហំទុនវិនិយោគចាប់ពី ០២(ពីរ) លានដុល្លារអាមេរិកឡើងទៅ ។

២- គំរោងវិនិយោគដែលមានទីតាំងស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ខេត្ត-ក្រុង ចាប់ពីពីរឡើងទៅ ។

៣- គំរោងវិនិយោគដែលស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ។

មាត្រា៧: នីតិវិធីនៃការចុះបញ្ជីសំណើវិនិយោគ និងផ្តល់ការលើកទឹកចិត្តវិនិយោគរបស់អនុគណៈកម្មាធិការវិនិយោគខេត្តព្រៃវែង គឺ :

- ដើរតួជាយន្តការច្រកចេញ-ចូលតែមួយលើការងារវិនិយោគនៅក្នុងខេត្ត
- ត្រូវអនុវត្តតាមនីតិវិធី ដោយផ្អែកលើច្បាប់-បទប្បញ្ញត្តិស្តីពីវិនិយោគជាធរមាន ដូចដែលអនុវត្តនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជាដែរ ។

មាត្រា៨: ការវិនិយោគទាំងឡាយណា ដែលបានទទួលការអនុញ្ញាតដោយច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ និងអនុក្រឹត្យពាក់ព័ន្ធនានា ត្រូវចាត់ទុកជាគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្រោយពេលអ្នកវិនិយោគបានបំពេញរាល់បែបបទតាមនីតិវិធីកំណត់ ដូចមានចែងក្នុងអនុក្រឹត្យ ស្តីពីការណែនាំអនុវត្តច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា៩: - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញបទប្បញ្ញត្តិ ស្តីពីការណែនាំអនុវត្តជាក់ស្តែង និងធ្វើការបណ្តុះបណ្តាលមុខជំនាញដល់អនុគណៈកម្មាធិការវិនិយោគខេត្តព្រៃវែង ដើម្បីធានាអោយដំណើរការនៃយន្តការនេះប្រព្រឹត្តិទៅមានភាពរលូន និងមានប្រសិទ្ធភាពខ្ពស់ ។

- អនុគណៈកម្មាធិការវិនិយោគខេត្តព្រៃវែង ត្រូវធ្វើរបាយការណ៍ប្រចាំខែមកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា ដើម្បីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា មានមូលដ្ឋានគ្រប់គ្រាន់សំរាប់ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល ។

មាត្រា១០: សហប្រធាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី-សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ-រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម-រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល-រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន-រដ្ឋមន្ត្រីក្រសួងបរិស្ថាន-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់-រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ-រដ្ឋមន្ត្រីក្រសួងផែនការ-រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម-រដ្ឋមន្ត្រីក្រសួងទេសចរណ៍-រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍-រដ្ឋមន្ត្រីគ្រប់ក្រសួង-អភិបាលខេត្តព្រៃវែង-អភិបាលគ្រប់ខេត្ត/ក្រុង-គ្រប់ប្រធានស្ថាប័ន/អង្គភាពដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងមាត្រា១ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

គាត ឈន់

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី សហប្រធាន"ក.អ.ក"
- ខុទ្ទកាល័យសម្តេចក្រុមព្រះ សហប្រធាន"ក.អ.ក"
- ដូចមាត្រា ១០ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ១១៨ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការរៀបចំសមាសភាពគណៈកម្មាធិការជាតិអប់រំសំរាប់ទាំងអស់គ្នា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ/បក ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអប់រំសំរាប់ទាំងអស់គ្នា
- បានឃើញអនុក្រឹត្យលេខ ១៦៨ អនក្រ/គត ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការរៀបចំសមាសភាពគណៈកម្មាធិការជាតិអប់រំសំរាប់ទាំងអស់គ្នា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

សំរេច

មាត្រា ១.-

គណៈកម្មាធិការជាតិអប់រំសំរាប់ទាំងអស់គ្នា (គ.ជ.អ.ទ) រួមមានសមាសភាពដូចខាងក្រោម :

១.	ឯកឧត្តម កុល ផេង	ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា	ប្រធាន
២.	ឯកឧត្តម អ៊ុម សិទ្ធី	រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា	អនុប្រធាន

៣. ឯកឧត្តម ព្រំ សុខា	រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	អនុប្រធាន
៤. ឯកឧត្តម ងី តាយី	អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	សមាជិក
៥. ឯកឧត្តម ញ៉ឹក សាមឿន	អនុរដ្ឋលេខាធិការក្រសួងផែនការ	សមាជិក
៦. ឯកឧត្តម ម្យាស់ លាស់	អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៧. ឯកឧត្តម ឧត្តមសេនីយ៍ត្រី ពេជ្រ សូជេត្ថា	អនុរដ្ឋលេខាធិការក្រសួងការពារជាតិ	សមាជិក
៨. ឯកឧត្តម លឹម គង់	អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ	សមាជិក
៩. លោកជំទាវ ជូ ប៊ុនអេង	អគ្គនាយកបច្ចេកទេសក្រសួងកិច្ចការនារី	សមាជិក
១០. ឯកឧត្តម វ៉ូ គឹមបោ៉រ	អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល	សមាជិក
១១. ឯកឧត្តម មាស គឹមសុភ័រ្ស	អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	សមាជិក
១២. ឯកឧត្តម កែវ បូរេន្រ្ត	អគ្គនាយកនៃអគ្គនាយកដ្ឋានសង្គមកិច្ច និង យុវនីតិសម្បទា នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា	សមាជិក
១៣. ឯកឧត្តម ទុយ គឿន	សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ នៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ	សមាជិក
១៤. ឯកឧត្តម ស៊ូ ស៊ុម	អនុរដ្ឋលេខាធិការក្រសួងពត៌មាន	សមាជិក
១៥. ឯកឧត្តម ដោក ណារិន	អនុរដ្ឋលេខាធិការក្រសួងធម្មការ និង កិច្ចការសាសនា	សមាជិក
១៦. ឯកឧត្តម លាភ វណ្ណដេន	អគ្គលេខាធិការរងនៃគណៈកម្មាធិការនីតិសម្បទា និង អភិវឌ្ឍន៍នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	សមាជិក

មាត្រា ២.-

សមាជិកគណៈកម្មាធិការទាំងអស់ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

មាត្រា ៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង ឯកឧត្តម លោកជំទាវ ដែលមាននាមចែងក្នុងមាត្រា១ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៥

ហ៊ុន សែន

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

" ដើម្បីសុំហត្ថលេខា "

គួល ផេង

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

និង ជាប្រធាន គ.ជ.អ.ឧ

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- កាលប្បវត្តិ - ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧០ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការដាក់មន្ត្រីរាជការអោយចូលនិវត្តន៍

* * ***

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- យោងតាមសំណើរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

សម្រេច

មាត្រា ១ : ត្រូវបានដាក់ឱ្យចូលនិវត្តន៍ក្នុងឋានន្តរស័ក្តិវរៈមន្ត្រី នូវមន្ត្រីក្របខ័ណ្ឌគ្រប់គ្រងរដ្ឋបាលចំនួន០៤ រូប របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្នុងឆ្នាំ២០០៤ ដូចមានរាយនាមខាងក្រោម :

១- លោក **ពេជ កែវ**	កើតថ្ងៃទី ៣០.១២.៤៤	ជាអគ្គនាយករង
២- លោក **ផាន់ សារ៉ាត់**	កើតថ្ងៃទី ២៦.១១.៤៤	ជាអគ្គនាយករង
៣- លោក **ហោ ឡុត**	កើតថ្ងៃទី ១៥.១០.៤៤	ជាព្រឹទ្ធបុរសមហាវិទ្យាល័យ
៤- លោក **អ៊ឹម មុន្នីសិរីញ**	កើតថ្ងៃទី ២១.០៤.៤៤	ជាព្រឹទ្ធបុរសមហាវិទ្យាល័យ

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង -ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ២
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១២១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការអនុញ្ញាតអោយមន្ត្រីរាជការចូលបំរើការងារ

* * ***

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.តត ចុះថ្ងៃទី១៩ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការដាក់មន្ត្រីរាជការស៊ីវិលអោយស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស
- យោងតាមសំណើរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

មាត្រា ១ : បន្ទាប់ពីបានឈប់សំរាកការងារអស់រយៈពេល០២ឆ្នាំ ដោយគ្មានបៀវត្សរួចមក លោក **ជា ឆណី** ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការវិនិយោគនិងទំនាក់ទំនងអន្តរជាតិ នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ត្រូវបានអនុញ្ញាតឱ្យចូលបំរើការងារវិញ គិតចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៤ តទៅ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង- ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល

ដូចមាត្រា ២
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ១៧២ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

* * ***

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមសំណើរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងលោក **មេងហុង សុជាតិខេមរ៉ូ** ជា **អគ្គនាយករង** នៃអគ្គនាយកដ្ឋានរៀបចំដែនដី នគរូបនីយ-កម្ម និងសំណង់ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង- ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ២
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៤៣ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ ..

ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូនលោកឧត្តមសេនីយ៍ទោ **ជួន សោខឃាត់** អត្តលេខ ០៥១៣ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ ..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧៤ អនក្រ . តត

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីការលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ៧៧ / អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

សំរេច

មាត្រា១ : តែងតាំងលោក **ជៀម ឡាយ៉ាឌីន** ជាអគ្គទីប្រឹក្សាស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋកូរ៉េ ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១២៥ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការសំរួលភារកិច្ច និងតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ .

សម្រេច

មាត្រា ១ : ត្រូវបានសំរួលភារកិច្ចលោក **ទឹម ណាត** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៧ ពីអភិបាលស្រុកស្វាយទាប ឱ្យមកបំរើការងារនៅសាលាខេត្តស្វាយរៀង ដោយរក្សាឋានន្តរសក្តិ និងថ្នាក់ដដែល ។

មាត្រា ២ : ត្រូវបានតែងតាំងលោក **សំ ថា** ឋានន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ ៣ ជាអភិបាលស្រុកស្វាយទាប ខេត្តស្វាយរៀង ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ០១ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៧៦ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការសំរួលភារកិច្ច និងតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ .

សម្រេច

មាត្រា ១ : ត្រូវបានសំរួលភារកិច្ចលោក **ឡៃ សុផាន** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៦ ពីអភិបាលស្រុកបវេល អោយមកបំរើការងារនៅសាលាខេត្តបាត់ដំបង ដោយរក្សាឋានន្តរសក្តិ និងថ្នាក់ដដែល ។

មាត្រា ២ : ត្រូវបានតែងតាំងលោក **នឹម ជាវ៉េត** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ ជាអភិបាលស្រុកបវេល ខេត្តបាត់ដំបង ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ២ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២៣ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៩អនក្រ បក ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមសំណើ របស់រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌

ស ម្រេ ច

មាត្រា១: ត្រូវបានតែងតាំង លោក **ជួន គេច** ជាអគ្គាធិការរង នៃអគ្គាធិការដ្ឋានកិច្ចការតុលាការ នៃក្រសួងយុត្តិធម៌ ។

មាត្រា២: បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យ នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ២ ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសុវត្ថារា

៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា .

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួង សាធារណការ និង ដឹកជញ្ជូន

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **អស្សឫទ្ធិ** ជូនឯកឧត្តមអគ្គនាយក អគ្គាធិការ ចំនួន០៧រូប ក្រោមឱវាទក្រសួងសាធារណការ និង ដឹកជញ្ជូន ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជំនាញជូនក្រសួង ដូចមានរាយនាមខាងក្រោម :-

១- ឯកឧត្តម **ស្នួត សំបុរ**	អគ្គនាយក នៃ អគ្គនាយកដ្ឋានរដ្ឋបាល
២- ឯកឧត្តម **ឈឺន គង់ហ៊ាន**	អគ្គនាយក នៃ អគ្គនាយកដ្ឋានសាធារណការ
៣- ឯកឧត្តម **ឃឹម រាជលិញ**	អគ្គាធិការ នៃ អគ្គាធិការដ្ឋាន
៤- ឯកឧត្តម **ឡេង ធនយុទ្ធា**	អគ្គនាយក នៃ អគ្គនាយកដ្ឋានដឹកជញ្ជូន
៥- ឯកឧត្តម **ហ៊ី ឆាវី**	អគ្គនាយក នៃ កំពង់ផែស្វយ័តភ្នំពេញ
៦- ឯកឧត្តម **សេរ វណ្ណា**	អគ្គនាយក នៃ ភ្នាក់ងារកម្ពុជានាវាចរ
៧- ឯកឧត្តម **សុខុម គគវន្តមុនី**	ប្រធានអគ្គនាយក នៃ រាជាយស្ម័យយានកម្ពុជា

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវ អនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួលៈ

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច ✓
B.105 -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៥១៧ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយការងារ

ចាប

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា .

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួង សាធារណការ និង ដឹកជញ្ជូន

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ក្រោមឱវាទ ក្រសួងសាធារណការ និង ដឹកជញ្ជូន ចំនួន ៦៨៥ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ មានរាយនាមខាងក្រោម :-

ក-មេដាយមាសការងារ ចំនួន៣៤ រូប :

១- លោក **ទង់ សំអាត** អគ្គនាយករង នៃ អគ្គនាយកដ្ឋានរដ្ឋបាល

២- លោកស្រី **ម៉ិន មាណវី** នាយិកា នៃ នាយកដ្ឋានរដ្ឋបាល

៣- លោក **ម៉ា ស៊ីមសុរិយា** នាយក នៃ នាយកដ្ឋានផែនការ

៤- លោក **លឹម ស៊ីដេនីន** នាយក នៃ នាយកដ្ឋានផ្លូវថ្នល់

៥- លោក **ម៉ាន់ ថន** នាយករង នៃ នាយកដ្ឋានរដ្ឋបាល

៦- លោក **ដួង ពេជ្រ** នាយករង នៃ នាយកដ្ឋានបុគ្គលិក-ធនធានមនុស្ស

៧- លោក **សុក ស៊ីអាន** នាយករង នៃ នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ

៨- លោក **ស៊ុខ សុគន់** នាយករង នៃ នាយកដ្ឋានផែនការ

៩- លោក **ឆន់ ចន** នាយករង នៃ នាយកដ្ឋានផ្លូវថ្នល់

១០- លោក ហោ លឹមសេង នាយករង នៃ នាយកដ្ឋានផ្លូវថ្នល់
១១- លោក ស៊ិន ចាន់ឌុល នាយករង នៃនាយកដ្ឋានផ្លូវទឹក
១២- លោក ទៅ ធនារត្ន នាយករង នៃ នាយកដ្ឋានសំណង់ផ្លូវអាកាស
១៣- លោក អៀង ម៉េងស៊ុន នាយកអាជីវកម្ម នៃ កំពង់ផែស្វយ័តភ្នំពេញ
១៤- លោក អាន សំអុល នាយកបច្ចេកទេស វិស្វកម្ម នៃ កំពង់ផែស្វយ័តភ្នំពេញ
១៥- លោក មន្ត អ៊ីណន់ នាយករដ្ឋបាល គ្រប់គ្រង នៃ កំពង់ផែស្វយ័តភ្នំពេញ
១៦- លោក អ៊ិច សម្បត្តិ នាយកផែនការ នៃភ្នាក់ងារកម្ពុជានាវាចរ
១៧- លោក ចាន់ ចារី នាយកអាជីវកម្ម នៃភ្នាក់ងារកម្ពុជានាវាចរ
១៨- លោក រិន ចឿន នាយកអាជីវកម្មដឹកជញ្ជូន នៃរាជាយស្វ័យយានកម្ពុជា
១៩- លោក ឌូ សារ៉ា នាយករដ្ឋបាល នៃរាជាយស្វ័យយានកម្ពុជា
២០- លោក លី ម្លិន នាយកផ្លូវ ស្ពាន អាគារ នៃរាជាយស្វ័យយានកម្ពុជា
២១- លោក ហ៊ុយ រិទ្ធ នាយកក្បាលម៉ាស៊ីន ទូរភ្លើង នៃរាជាយស្វ័យយានកម្ពុជា
២២- លោក ចន្ទី សំឡេង នាយករងផ្លូវ ស្ពាន អាគារ នៃរាជាយស្វ័យយានកម្ពុជា
២៣- លោក សេង ឈុន ប្រធានកំពង់ចម្លងអ្នកលឿង
២៤- លោក គន់ ជួន ប្រធានសេវាដ្ឋានបច្ចេកទេស ស្រាវជ្រាវ នៃកំពង់ផែស្វយ័តភ្នំពេញ
២៥- លោក សុខ សាយ នាយកមន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្តព្រៃវែង
២៦- លោក យិន ម៉ុនណារ៉ា ប្រធានការិយាល័យគណនេយ្យ-ហិរញ្ញវត្ថុ នៃភ្នាក់ងារកម្ពុជានាវាចរ
២៧- លោក ហុក ម្លិះ នាយករង មន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្តកោះកុង
២៨- លោក ស៊ុន សិន នាយករង មន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្តបន្ទាយមានជ័យ
២៩- លោក ខាន់ ម៉ាណែរ នាយករង មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តបាត់ដំបង
៣០- លោក គី ធារិទ្ធ នាយករង មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តបាត់ដំបង
៣១- លោក អ៊ុំ អួក នាយករង មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តតាកែវ
៣២- លោក ឈុំ ឃេង នាយករងមន្ទីរសាធារណការនិងដឹកជញ្ជូន ក្រុងព្រះសីហនុ
៣៣- លោក ពេជ ជន់ អនុប្រធាន កំពង់ចម្លងអ្នកលឿង
៣៤- លោក ហោក់ ចន្ថា អនុប្រធាន កំពង់ចម្លងអ្នកលឿង

ខ/ **មេដាយស្នាដៃការងារ ចំនួន ១៦៩ រូប :**

១- លោក សុខ ស្រ៊ុន នាយករង មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តកំពង់ចាម
២- លោក ឈិន ឈុនលីម នាយករង មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តបាត់ដំបង
៣- លោក ប្រាក់ សារ៉ែម នាយករង មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តពោធិសាត់
៤-លោក ស្រ៊ីម គីម នាយករង មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តពោធិសាត់

៥- លោក	**ភាព បើងហាក់**	នាយករង មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តពោធិសាត់
៦- លោក	**ជីញ គួច**	នាយករង មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តពោធិសាត់
៧- លោក	**ឡូយ កែ**	នាយករងមន្ទីរសាធារណការនិងដឹកជញ្ជូន ខេត្តព្រៃវែង
៨- លោក	**ចន្ទំ ធីន**	នាយករងមន្ទីរសាធារណការនិងដឹកជញ្ជូន ខេត្តព្រៃវែង
៩- លោក	**សោម សារឹម**	នាយករង មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តសៀមរាប
១០- លោក	**លឹម សុខគ្រី**	នាយករង មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តសៀមរាប
១១- លោក	**សួន វុត្ថា**	នាយករង មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តកំពត
១២- លោក	**ម៉ឹង ឆួច**	នាយករង មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តកំពត
១៣- លោក	**កៅ កុសល**	នាយករង មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តកំពង់ឆ្នាំង
១៤- លោក	**ស្រី ហួយ**	នាយករង មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តស្វាយរៀង
១៥- លោក	**សំ សាខុន**	នាយករង មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តស្វាយរៀង
១៦- លោក	**ឆនី សុឆា**	នាយករង មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តតាកែវ
១៧- លោក	**ពុំ សម្ភោរ**	នាយករង មន្ទីរសាធារណការ និង ដឹកជញ្ជូន ក្រុងព្រះសីហនុ
១៨- លោក	**ស្រេង ស្រស់**	នាយករង មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តក្រចេះ
១៩- លោក	**ផាន់ វឈឿន**	នាយករង មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តស្ទឹងត្រែង
២០- លោក	**ហ៊ុយ ហេង**	នាយករង មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តមណ្ឌលគិរី
២១- លោក	**អ៊ាន សារ៉ាត់**	នាយករង មន្ទីរសាធារណការ និង ដឹកជញ្ជូន ក្រុងប៉ៃលិន
២២- លោក	**អ៊ុម គីមស៊ុន**	នាយករង មន្ទីរសាធារណការ និង ដឹកជញ្ជូន ក្រុងកែប
២៣- លោក	**អ៊ូ ពៅ**	នាយករង មន្ទីរសាធារណការ និង ដឹកជញ្ជូន ក្រុងកែប
២៤- លោក	**ឆង់ គីមឈាន**	នាយការិយាល័យ បុគ្គលិក នៃនាយកដ្ឋានបុគ្គលិក-ធនធានមនុស្ស
២៥- លោក	**អ៊ុក ចន្ទតារា**	នាយការិយាល័យ ថវិកានិងហិរញ្ញកិច្ច នៃនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ
២៦- លោក	**ឡុង ហ៊ុន**	នាយការិយាល័យ គ្រប់គ្រងទិន្នន័យស្ថិតិ ពត៌មាន នៃ នាយកដ្ឋានផែនការ
២៧- លោកស្រី	**ខួន គុននារី**	នាយការិយាល័យ ពិធីការ នៃនាយកដ្ឋានរដ្ឋបាល
២៨- លោក	**ឈឹម ឆេន**	នាយកការិយាល័យ រដ្ឋបាល បុគ្គលិក គណនេយ្យ នៃនាយកដ្ឋានផ្លូវថ្នល់
២៩- លោក	**ម្រិច ហារីង**	ប្រធានអង្គភាព ថ្នល់ នៃនាយកដ្ឋានផ្លូវថ្នល់
៣០- លោក	**អ៊ុក ស៊ីសារ៉ូ**	នាយការិយាល័យ សំភារៈ និងគ្រឿងចក្រ នៃមជ្ឈមណ្ឌលគ្រឿងចក្រធំ ១
៣១- លោក	**ចេង សុខេង**	ប្រធានអង្គភាព អន្តរាគមន៍ នៃមជ្ឈមណ្ឌលគ្រឿងចក្រធំ ១

៣២- លោក នូ វឌ្ឍនះ នាយការិ. ស្រាវជ្រាវនិងហេដ្ឋារចនាសម្ព័ន្ធ នៃមជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេស

៣៣- លោក រិន សុឌ្ឋី នាយការិយាល័យ រដ្ឋបាល បុគ្គលិក នៃនាយកដ្ឋានសំណង់ផ្លូវអាកាស

៣៤- លោក ផង់ សំ នាយរងការិ. លទ្ធកម្ម និងសាងសង់នៃនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ

៣៥- លោក អ៊ូម សំអឿន នាយរងការិ. ទ្រព្យរដ្ឋ សហគ្រាសសាធារណៈ នៃនាយកដ្ឋានគណនេយ្យ- ហិរញ្ញវត្ថុ

៣៦- លោកស្រី សុខ សុគន្ធា នាយរងការិ. ថវិកា ហិរញ្ញកិច្ច នៃនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ

៣៧- លោក ជា សុផាណែត នាយរងការិ. គ្រប់គ្រងទិន្នន័យ ស្ថិតិ ពតិមាន នៃនាយកដ្ឋានផែនការ

៣៨- កញ្ញា គួច ម៉ារីអ៊ី នាយរងការិ.ផ្ទៀងផ្ទាត់និងគ្រប់គ្រងទិន្នន័យ នៃនាយកដ្ឋានបុគ្គលិក-ធនធានមនុស្ស

៣៩- លោក ខែត រដ្ឋា នាយរងការិយាល័យ កិច្ចការទូទៅ នៃនាយកដ្ឋានរដ្ឋបាល

